រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

057KH01A-01

ការឈ្នះលើភាពងងឹត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥៧

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

រាជ្យមានពីរ

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចែងប្រាប់យើងយ៉ាងច្បាស់ថា សព្វថ្ងៃនេះមានរាជ្យខាងព្រលឹងវិញ្ញាណពីរ ដែលប្រឆាំងគ្នាទៅវិញទៅមក គឺព្រះរាជ្យរបស់ព្រះជាម្ចាស់ និង រាជ្យរបស់មារសាតាំង ។ មនុស្សម្នាក់ៗត្រូវតែស្ថិតក្នុងការគ្រប់គ្រងរបស់រាជ្យណាមួយ (ម៉ាថាយ ១២:៣០) ។

ព្រះជាម្ចាស់ជាព្រះអាទិករបង្កើតអ្វីៗសព្វសារពើ ហើយអ្វីៗគ្រប់យ៉ាង សុទ្ធតែល្អឥតខ្ចោះ កាលពីដើមដំបូងបង្អស់ ។ ព្រះជាម្ចាស់ ជាព្រះមហាក្សត្រជារៀងរហូតមក ហើយព្រះអង្គនឹងនៅតែជាព្រះមហាក្សត្រជាដរាបតទៅ (យេរេមី ១០:៧) ។ ប៉ុន្តែ ព្រះគម្ពីរបានចែងប្រាប់ថា ទេវទូតអ្នកដឹកនាំគេម្នាក់របស់ព្រះជាម្ចាស់ឈ្មោះលូស៊ីហ្វឺ បានមានចិត្តព្រហើន ព្រោះតែមានរូបសម្បត្តិដ៏ល្អស្អាត (អេសេគីអែល ២៨:១៤-១៧) ហើយនិយាយថា÷

«យើងនឹងឡើងទៅលើមេឃ ហើយលើកបល្ល័ង្ករបស់យើងឡើងអោយខ្ពស់ជាងផ្កាយរបស់ព្រះជាម្ចាស់ទៅទៀត ។ យើងនឹងអង្គុយលើភ្នំ នៅខាងជើងបំផុត...» ។

(អេសាយ ១៤:១៣-១៤)

កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- រៀនអោយចេះច្បាស់អំពីខ្លឹមសាររបស់ការសិក្សានេះ ដើម្បីអាចធ្វើកិច្ចការបំរើជួយពួកអ្នក ដែលនៅក្រោមអំណាចរបស់មារសាតាំង ។
- បន្ទាប់មក បង្រៀនខ្លឹមសាររបស់ការសិក្សានេះ ដល់ពួកអ្នកជឿចាស់ទុំ ដែលអ្នកអាចនាំអោយចូលរួមធ្វើជាក្រុមមួយ ដើម្បីអនុវត្តកិច្ចការបំរើនេះ ។
- អធិស្ឋានសំរាប់សហគមន៍របស់អ្នក ទូលសូមអោយព្រះ-ជាម្ចាស់កំទេចអំណាចគ្រប់យ៉ាងរបស់មារសាតាំង ដែលមានឥទ្ធិពលលើសហគមន៍ ។



ចាប់ពីពេលនោះមក លូស៊ីហ្វើ «អ្នកដែលមានពន្លឺភ្លឺផ្លេក» បានក្លាយជាមារសាតាំង«ខ្មាំងសត្រូវ» ហើយត្រូវព្រះជាម្ចាស់បណ្តេញចេញពីស្ថានបរមសុខជាមួយនឹងទេវទូតជាច្រើន ដែលធ្លាក់ចុះជាមួយលូស៊ីហ្វើនោះ ។

ក្រោយពីព្រះជាម្ចាស់ បានបង្កើតសកលទ្វីបលោករបស់ព្រះអង្គគ្រប់លក្ខណៈឥតខ្ចោះ និង អស្ចារ្យហើយ មារសាតាំងក៏បានល្បួងដួនតាដំបូងរបស់យើងឱ្យលែងស្តាប់បង្គាប់ព្រះជាម្ចាស់ (កំណើតពិភពលោក ៣:៤, អេភេសូ ២:២, ១ យ៉ូហាន ៣:៨) ។ ចាប់ពីពេលនោះមក មនុស្សទាំងអស់ដែលកើតមក សុទ្ធតែស្ថិតក្រោមអំណាចនៃរាជ្យរបស់មារសាតាំង ។ លូស៊ីហ្វើបានធ្វើបាបដំបូងបង្អស់ នៅក្នុងពិភពព្រលឹងវិញ្ញាណ ។

តើអំពើបាបនោះជាអ្វី ? ។ _____

ព្រះជាម្ចាស់ក៏ធ្វើសកម្មភាពតទល់នឹងស្ថានភាពនេះ :

- ព្រះជាម្ចាស់ចាត់ព្រះបុត្រាព្រះអង្គ គឺព្រះយេស៊ូមកក្នុងពិភពលោកនេះ ដើម្បីបំផ្លាញរាជ្យរបស់មារសាតាំង និង កិច្ចការអាក្រក់របស់វា (យ៉ូហាន ១២:៣១, ១ យ៉ូហាន ៣:៨) និង ដើម្បីរៀបចំព្រះរាជ្យរបស់ព្រះជាម្ចាស់ (ម៉ាថាយ ១២:២៨) ។

- នៅលើឈើឆ្កាង ព្រះយេស៊ូគ្រីស្តបានទទួលទោសនៃអំពើបាបរបស់យើងរាល់គ្នា ហើយបានរំដោះយើងអោយរួចពីរាជ្យរបស់អារក្ស (កូឡុស ១:១៣-១៤, ២:១៥, ហេប្រឺ ២:១៤-១៥) ។ នៅពេលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះជាម្ចាស់បានតែងតាំងព្រះយេស៊ូ *«ជាព្រះបុត្រាប្រកបដោយឫទ្ធានុភាព»* ហើយព្រះយេស៊ូបានទទួល *«គ្រប់អំណាច ទាំងនៅស្ថានបរមសុខ ទាំងនៅលើផែនដី»* (រ៉ូម ១:៤, ម៉ាថាយ ២៨:១៨) ។

- ឥឡូវនេះ បើសិនជាយើងកែប្រែចិត្តគំនិត ហើយទទួលជឿលើព្រះយេស៊ូគ្រីស្ត នោះយើងនឹងចេញពីរាជ្យរបស់មារសាតាំង ហើយចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ (យ៉ូហាន ៣:៥) ។

- មនុស្សដែលព្រះជាម្ចាស់បានរំដោះហើយ តែងតែត្រូវការមនុស្សអោយជួយផ្តល់យោបល់ និង ជួយក្នុងការរស់នៅជាគ្រីស្តជន ។ មួយវិញទៀត ត្រូវជួយអោយមនុស្សនោះអាចចូលរួមក្នុងក្រុមជំនុំ ដើម្បីអាចបានរៀនសូត្រ និង មានមេត្រីភាពជាមួយគ្រីស្តជនឯទៀតបាន គឺត្រូវការអោយគ្រីស្តជនឯទៀតលើកទឹកចិត្ត និងរាប់អានខ្លួនដែរ ។

- ក្រោយដែលបានជួយរំដោះមនុស្ស ដែលទទួលឥទ្ធិពលបិសាច ឬ មនុស្សខ្មោចចូលហើយ យើងត្រូវថ្វាយសិរីរុងរឿងគ្រប់យ៉ាងដល់ព្រះជាម្ចាស់ មិនមែនយើងអួតខ្លួនទេ ។ ព្រះអម្ចាស់យេស៊ូគ្រីស្តរបស់យើងមានបន្ទូលថា÷ *«កុំត្រេកអរនឹងឃើញខ្មោចចុះចូលអ្នករាល់គ្នា គឺត្រូវត្រេកអរ ដោយអ្នករាល់គ្នាមានឈ្មោះកត់ទុកនៅស្ថានបរមសុខវិញ»* (លូកា ១០:២០) ។

- បន្ទាប់មក អធិស្ឋានទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធ បំពេញមនុស្សនោះពេញលេញ ជាពិសេស យកចិត្ត ទុកដាក់ស្តារផ្នែកណា ដែលត្រូវបិសាចបណ្តាលអោយ មានបញ្ហា ។ ឧ. បើសិនជាខ្មោចចូលបណ្តាលអោយ មានការភ័យខ្លាច យើងអាចទូលសូមឱ្យព្រះវិញ្ញាណដ៏ វិសុទ្ធប្រទានអោយមនុស្សនោះមានជំនឿ និង ទុកចិត្ត គ្រប់យ៉ាងលើព្រះគ្រីស្ត ។

- មនុស្សនោះខ្លួនឯង ត្រូវធ្វើសកម្មភាពដែរ ដើម្បីបង្ហាញ ថា ខ្លួនបដិសេធមិនទទួលខ្មោចទៀតទេ ដោយបំផ្លាញ វត្ថុ ឬ សៀវភៅគ្រប់យ៉ាង ដែលជាប់ទាក់ទងនឹងអាបធ្មប់ ឬ អំពើមន្តអាគម ។

- ការលប់បំបាត់មូលហេតុ ដែលនាំអោយខ្មោចអាចចូល បាន ជាការសំខាន់ណាស់ ដើម្បីកុំអោយខ្មោចអាច ចូលបានទៀត ។ ភាគច្រើន មនុស្សរងគ្រោះ ត្រូវ ឈប់ប្រព្រឹត្តអំពើបាបណាមួយ ឬ អត់ទោសអោយអ្នក ដែលបានធ្វើខុសមកលើគេ (អាចជាមនុស្សជិតស្និទ្ធ ផ្ទាល់ខ្លួន ដូចជាឪពុកម្តាយដែលកាចសាហាវ ។ល។) ជាចាំបាច់ ។

- ព្រះរាជ្យរបស់ព្រះជាម្ចាស់ ក៏រីកសាយដោយរបៀបនេះ គឺ ដោយកំទេចរាជ្យរបស់មារសាតាំង តាមរយៈកិច្ចការបំរើ របស់ក្រុមជំនុំ (ម៉ាថាយ ១០:១-៨, អេភេសូ ៣:១០, ១ យ៉ូហាន ៣:៨) ។

- នៅពេលដែលព្រះអម្ចាស់យេស៊ូយាងមកវិញ នោះព្រះរាជ្យ របស់ព្រះជាម្ចាស់នឹងយាងមក ប្រកបដោយអំណាចរបស់ ព្រះជាម្ចាស់ រីឯមារសាតាំង ព្រមទាំងរាជ្យរបស់វា នឹងត្រូវ រលាយសាបសូន្យ (ម៉ាថាយ ១៣:៣៦-៤៣, វិវរណៈ ២០:៧-១០) ។

ក្នុងចំណោមរាជ្យទាំងពីរដែលប្រឆាំងគ្នានេះ តើរាជ្យណាមួយមាន ជ័យជំនះ ? ។ _____

រាជ្យរបស់មារសាតាំង

ក្នុងរាជ្យរបស់មារសាតាំង មានកិរិតអំណាចផ្សេងគ្នា :



«ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹងវត្ថុសក្តិសិទ្ធិ ទល់នឹងអ្វីៗដែលមានអំណាច ទល់នឹងមេត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹតនេះ ហើយតយុទ្ធទល់នឹងឥទ្ធិពលអរូបិយដ៏អាក្រក់ទាំងឡាយ ដែលនៅស្ថានលើដែរ » ។

(អេភេសូ ៦:១២)

សូមចាំថា អារក្សក៏ចេះភ័យញ័រដែរ (យ៉ាកុប ២:១៩) ។ ខ្មោចអាចចេញពីមនុស្សភ្លាមៗ ដោយក្តុងក្តាំង ឬ ស្ងៀមស្ងាត់ ។ អ្នកអាចដឹង នៅពេលដែលខ្មោចចេញពីមនុស្ស ដោយសារបទពិសោធន៍ និង ការមើលដឹងដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ។

៤- ជួយអោយមនុស្សធ្លាប់ខ្មោចចូល មានសភាពធម្មតាវិញ ។ ភារៈកិច្ចមិនមែនត្រូវចប់នៅពេលខ្មោចចេញទេ ។ គោលដៅ គឺជួយអោយមនុស្សនោះ មានសភាពធម្មតាពេញលេញឡើងវិញ ដើម្បីកុំអោយខ្មោចអាចត្រឡប់មកវិញ (ម៉ាថាយ ១២:៤៣-៤៥, ម៉ាកុស ៩:២៥) ។

- មានតែព្រះយេស៊ូទេ ដែលអាចបំពេញកន្លែងទំនេរក្នុងខ្លួនមនុស្ស ក្រោយពេលដេញខ្មោចចេញហើយ ។ ដូចនេះ ទើបយើងត្រូវពន្យល់ពីដំណឹងល្អប្រាប់មនុស្សធ្លាប់មានខ្មោចចូលនោះ ហើយអោយគេទទួលព្រះ-គ្រីស្ត មកគង់ក្នុងជីវិតរបស់ពួកគេ ។
- ត្រូវណែនាំមនុស្សនោះ អោយអធិស្ឋានលន់តួសារភាពអំពើបាប គឺបដិសេធលែងទាក់ទងនឹងខ្មោចបិសាចអាបធ្មប់ និង អំពើមន្តអាគមទៀត ។

- មារសាតាំងជាវិញ្ញាណ ដែលមានឥទ្ធិពលលើពួកប្រឆាំងនឹងព្រះជាម្ចាស់ (អេភេសូ ២:២) ។ មារសាតាំងជា «ព្រះនៃលោកីយ៍នេះ» (២ កូរិនថូស ៤:៤) ។
- នៅពីក្រោមមារសាតាំង មានពួកអ្នកមានអំណាច ពួកត្រួតត្រាក្នុងលោកីយ៍ដ៏ងងឹត និង ឥទ្ធិពលអរូបិយអាក្រក់នៅស្ថានលើដែរ (អេភេសូ ៦:១២) ។ ពួកវាហាក់ដូចជាស្ថិតនៅរាយគ្នាពាសពេញលោកីយ៍នេះ ដើម្បីត្រួតត្រា និង រៀបចំសកម្មភាពរបស់វា ។
- នៅក្រោមពួកអារក្សទាំងនេះ មានកងកម្លាំងខ្មោចបិសាចដែលមានឥទ្ធិពលលើមនុស្ស គឺ បណ្តាលអោយមានជម្ងឺ ការគាបសង្កត់ ការល្បួង ទំនាស់ និង សេចក្តីបង្រៀនក្លែងក្លាយ (អេភេសូ ៦:១២, ១ ធីម៉ូថេ ៤:១) ។

២- **សូមអោយអ្នករងគ្រោះ ប្រកាសយល់ព្រមចោះបង់លែងធ្វើអំពើចាប** ដែលគេបានលន់តួសារភាពហើយ រួចទូលសូមឱ្យព្រះជាម្ចាស់ជួយអោយគេមានសេរីភាពរួចពីឥទ្ធិពលរបស់អារក្ស ។ នៅក្នុងសម្ពន្ធមេត្រីចាស់ ពួកអ៊ីស្រាអែលមានសេរីភាពរួចពីការគាបសង្កត់របស់សត្រូវ នៅពេលដែលពួកគេអំពាវនាវរកព្រះអម្ចាស់ (វិនិបុរស ៤:១-៣) ។

៣- **ដេញអារក្សចេញ** ។ នៅពេលដែលអារក្សបង្ហាញវត្តមានរបស់វាអោយអាចមើលដឹង ត្រូវបញ្ជាដេញវាភ្លាម ដោយប្រើអំណាចរបស់ព្រះយេស៊ូ ។ បើអារក្សនិយាយតាមរយៈអ្នករងគ្រោះ ត្រូវបញ្ជាវាអោយនៅស្ងៀម (ម៉ាកុស ១:២៥) ។ ជជែកជាមួយអារក្ស គ្មានប្រយោជន៍អ្វីទេ ព្រោះវាមានន័ស្ប័យភរទៅហើយ (យ៉ូហាន ៨:៤៤, ១ ធីម៉ូថេ ៤:១) ។

តើពួកអារក្សមានសភាពដូចម្តេច ?

យោងទៅតាមសម្ពន្ធមេត្រីថ្មី អារក្ស :

- ជាវិញ្ញាណ (គ្មានរូបកាយ ម៉ាថាយ ១២:៤៣-៤៥, លូកា ២៤:៣៩) ។
- ប្រព្រឹត្តអំពើអាក្រក់ (ឃាតករ និង មេភរ ម៉ាថាយ ១២:៤៣-៤៥, កិច្ចការ ៨:៧, វិវរណៈ ១៦:១៣-១៤) ។
- មានកម្លាំង និង អំណាចខ្លាំងហួសពីធម្មតា (ម៉ាកុស ៥:៤, លូកា ៨:២៩, កិច្ចការ ១៩:១៣-១៦) ។
- មានប្រាជ្ញា (កិច្ចការ ១៦:១៦, កិច្ចការ ១៩:១៥-១៦) ។

ប៉ុន្តែ ទោះជាពួកអារក្សមានអំណាចក៏ដោយ ក៏ពួកវាគ្មានឫទ្ធានុភាព ដូចព្រះជាម្ចាស់ដែរ ។ ជួនកាល មនុស្សអាចគិតខុសថា មារសាតាំងស្មើនឹងព្រះជាម្ចាស់ គ្រាន់តែវាអាក្រក់ ។ គិតដូចនេះមិនត្រូវទាល់តែសោះ ព្រោះអារក្ស :

- ត្រូវព្រះជាម្ចាស់បង្កើតឡើង (ទេវទូតធ្លាក់ចុះ) ដូចនេះពួកវាមិនមានឥទ្ធិពលខ្ពស់លើសលប់ទេ ហើយក៏មិនអាចស្ថិតនៅគ្រប់ទីកន្លែងក្នុងពេលតែមួយបានដែរ និង មិនអាចដឹងអ្វីៗគ្រប់យ៉ាងដូចព្រះជាម្ចាស់ឡើយ ។

នៅពេលប្រឈមមុខតទល់នឹងមារសាតាំង អ្នកដែលប្រើព្រះនាមរបស់ព្រះយេស៊ូ ត្រូវជឿទាំងស្រុងលើអំណាចរបស់ព្រះអង្គ ដែលជាស្តេចលើអស់ទាំងស្តេច ហើយទុកចិត្តទាំងស្រុងថា ព្រះយេស៊ូឈ្នះលើមារសាតាំង ។

ដើម្បីរំដោះមនុស្សខ្មោចចូល តាមធម្មតា គេធ្វើតាមជំហានខាងក្រោមនេះ :

១- **សូមអោយអ្នករងគ្រោះលន់តួសារភាពអំពើបាបទាំងឡាយ** របស់ខ្លួន ដែលនាំអោយខ្មោចចូលមកក្នុងជីវិតខ្លួន ។ ណែនាំប្រាប់គាត់អំពីពលិកម្មរបស់ព្រះគ្រីស្ត ដែលបានមានព្រះជន្មឡើងវិញ និង ជ័យជំនះរបស់ព្រះអង្គនៅលើឈើឆ្កាង (អេសាយ ៥៣:៤-៦, កូឡូស ២:១៣-១៥) ។ ណែនាំពួកគេអោយបោះចោល ឬ លែងធ្វើអ្វីៗគ្រប់យ៉ាងដែលផ្តល់ឱកាសឱ្យអារក្សអាចមកគ្រប់គ្រងគាបសង្កត់លើពួកគេបាន (អេភេសូ ៤:២៧, យ៉ូហាន ១៤:៣០) ។

ការរំដោះមនុស្សដែលនៅក្រោមឥទ្ធិពលរបស់ខ្មោចបិសាច

យើងត្រូវមានជំនឿ និង អំណាចក្នុងព្រះគ្រីស្តធំណាស់ ដើម្បីរំដោះមនុស្សដែលមានខ្មោចចូល ។ ដូចនេះ បើសិនជាអ្នកគ្មានបទពិសោធន៍ក្នុងកិច្ចការនេះទេ យើងសូមទូន្មានកុំឱ្យអ្នកប្រថុយធ្វើកិច្ចការនេះតែម្នាក់ឯងឡើយ ។

ជួនកាល យើងត្រូវការអធិស្ឋានច្រើនម៉ោង និង ច្រើនដង មុននឹងអាចដេញបិសាចចេញបាន ។ កុំយកចិត្តទុកដាក់ចំពោះអារក្សហួសហេតុពេកអោយសោះ ។ មារសាតាំងចូលចិត្តឆាឆៅយើង និង ល្បួងយើងអោយធ្វើតាមគំរោងការណ៍របស់វាណាស់ ។ មិនត្រូវចូលទៅប្រកួតប្រណាំងជាមួយវាទេ ។ តែត្រូវបញ្ជាវាអោយចេញទៅ ដោយសារព្រះនាមព្រះយេស៊ូ រួចឈប់រវល់អើពើពីវា ដើម្បីកុំអោយយើងបណ្តាលអោយមានទុក្ខលំបាកខ្លាំងជាងមុន ។

អំណាចរបស់គ្រីស្តជនលើមារសាតាំង មិនមែនពឹងលើពិធី ឬ មន្តអាគមគាថាទេ តែពឹងលើការដែលគ្រីស្តជនជាអ្នកបំរើព្រះជា-ម្ចាស់ និង ជាបុត្រធីតារបស់ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ទៅវិញទេ ។ ព្រះនាមព្រះយេស៊ូមិនមែនត្រូវប្រើជាពាក្យសក្តិសិទ្ធិនោះទេ តែត្រូវប្រើដោយសាតាំងទទួលដឹងថា វាចាញ់តែព្រះអង្គប៉ុណ្ណោះ ។ យើងគ្រាន់តែជាឧបករណ៍របស់ព្រះអង្គទេ ។

- ត្រូវចុះចូលនឹងព្រះនាមរបស់ព្រះយេស៊ូ (ម៉ាកុស ៣:១១-១២, ម៉ាកុស ៥:៧, លូកា ៤:៣៦, លូកា ១០:១៧-២០) ។
- មិនអាចធ្វើអ្វីបាន បើគ្មានការអនុញ្ញាតិពីព្រះជាម្ចាស់ ។
- ដឹងពីវាសនាខ្លួនវាហើយ គឺបឹងភ្លើងដ៏នៅអស់កល្ប (ម៉ាថាយ ៨:២៩, ២៥:៤១, យ៉ាកុប ២:១៩) ។
- នឹងរត់គេចចេញពីយើង បើសិនជាយើងប្រឆាំងនឹងវា ដោយនូវព្រះនាមរបស់ព្រះអម្ចាស់ (យ៉ាកុប ៤:៧) ។

© Project WorldReach © SEAN

សូមគូររង្វង់ជុំវិញតួអក្សរ ដែលសំគាល់ថា ឃ្លាត្រូវ ឬ ខុស ។
អក្សរ «ត» ស្មើនឹង «ត្រូវ» និង អក្សរ «ខ» ស្មើនឹង «ខុស» :

ពួកអារក្ស :

១- ជាព្រលឹងមនុស្ស
ស្លាប់ ។ ត ខ

២- ជាទេវទូតដែលធ្លាក់
ចុះពីស្ថានបរមសុខ ។ ត ខ

៣- ជាព្រលឹងសត្វ ។ ត ខ

៤- មានឫទ្ធានុភាពគ្រប់
យ៉ាង ។ ត ខ

៥- ពេលខ្លះខ្វចខិល
ពេលខ្លះទៀតល្អ ។ ត ខ

៦- គ្មាននរណាអាច
កំទេចបាន ។ ត ខ

ចំលើយ : ១=ខ, ២=ត, ៣=ខ, ៤=ខ, ៥=ខ, ៦=ខ ។

៤- កំទេចវត្ថុគ្រប់យ៉ាង ដែលជាប់ទាក់ទងនឹងអំពើបាបណា
ដែលអ្នកកំពុងតស៊ូបំបាត់ ជាពិសេស វត្ថុ ឬ សៀវភៅ
ក្បួនតម្រាអំពីធ្មប់ ។

៥- បញ្ជាវិញ្ញាណអាក្រក់ ដែលអ្នកមើលដឹងជាក់ស្តែង អោយ
ចេញទៅ ដោយសារព្រះនាមព្រះយេស៊ូ ។ សុំអោយជនរង
គ្រោះអធិស្ឋានទូលសូមអោយព្រះជាម្ចាស់រំដោះខ្លួនគេ ឱ្យ
មានសេរីភាពដែរ ។ បន្ទាប់មក អធិស្ឋានទូលសូមអោយ
មនុស្សនោះបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអាច
ទប់ទល់នឹងការល្បួងរបស់អារក្ស ដែលចង់កៀបសង្កត់
ពួកគេម្តងទៀត នៅពេលក្រោយ ។

ពេលខ្មោចចេញពីមនុស្សដែលមានខ្មោចចូល អាចមិនឃើញមាន
ការអ្វីជាក់ស្តែង ដែលបង្ហាញថា ខ្មោចចេញទេ ។ បើមនុស្សពិត
ជាបានរំដោះរួចពីខ្មោចមែន សូមពន្យល់ប្រាប់ពួកគេអោយជឿថា
ព្រះជាម្ចាស់បានធ្វើកិច្ចការរបស់ព្រះអង្គហើយ និង សូមអោយគេ
បដិសេធការល្បួងគ្រប់យ៉ាងរបស់មារសាតាំង ដែលចង់សាប
ព្រោះការសង្ស័យ នៅក្នុងជីវិតរបស់គេ ។

អ្នកអាចណែនាំមនុស្សនោះ អោយធ្វើតាមជំហានទាំងនេះ :

១- ថ្វាយជីវិតទៅព្រះគ្រីស្តដោយជំនឿ គឺទូលសូមឱ្យព្រះគ្រីស្តធ្វើជាព្រះអម្ចាស់លើគ្រប់ផ្នែកនៃជីវិតរបស់ខ្លួនគេ ។

២- លន់តួសារភាព ហើយងាកចេញពីអំពើបាប និង សេចក្តីល្បួង ដែលនាំអោយគេមានបញ្ហា ។

៣- ប្រើអំណាច និង បុទ្ធានុភាពដែលពួកគេទទួលបាន ដោយសារពួកគេថ្វាយខ្លួនទៅព្រះគ្រីស្ត ហើយបញ្ជាដេញវិញ្ញាណអាក្រក់គ្រប់យ៉ាង ដែលពួកគេដឹងថា មានវត្តមាននៅក្នុងខ្លួនគេ អោយចេញភ្លាម ។ ពួកគេអាចធ្វើកិច្ចការនេះ ដោយអធិស្ឋានថា÷ «ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ខ្ញុំបញ្ជាអោយវិញ្ញាណដែលនាំអោយខ្ញុំភ័យខ្លាច ។ល។ ចេញពីខ្ញុំ ហើយកុំមកវិញទៀត » ។

តើមារសាតាំង និង ពួកអារក្សរបស់វា មានឥទ្ធិពលអាក្រក់មកលើយើងយ៉ាងដូចម្តេចខ្លះ ?

សង្គមមនុស្សជាអ្នករងគ្រោះទីមួយ ដោយសារមារសាតាំង ។ មារសាតាំងធ្វើអោយជាតិសាសន៍ទាំងឡាយធ្វើសង្គ្រាម (វិវរណៈ ២០:៧-៨) ស្អប់គ្នា និង ធ្វើអំពើអយុត្តិធម៌ ដូចជាពន្ធនាគារ រៀបការជាមួយភេទដូចគ្នា និង ប្រកាន់ពូជសាសន៍ និង វណ្ណៈក្នុងសង្គម ។ល។ (១ រាជក្សត្រ ២១:១) ។ បញ្ហារបស់មនុស្សសុទ្ធតែមានប្ញសគល់ចេញពីគំនិត ដែលបណ្តាលមកពីអារក្ស លើកលែងតែកំហុសមកពីអំពើបាបរបស់មនុស្សផ្ទាល់ ។ ឧទាហរណ៍ ភាពក្រីក្រ មនុស្សអាចកំចាត់លែងអោយមានបាន តែមារសាតាំងរារាំងការនេះ ដោយបណ្តាលអោយមានរង្វង់អាក្រក់នៃភាពក្រីក្រ :

រង់ខែភាពក្រីក្រ



រង់ខែសម្ភារៈនិយម





ជួនកាល មនុស្សរងគ្រោះខ្លួនឯង អាចកាត់ផ្តាច់ចំណងដែលមារ-សាតាំងចងខ្លួន ដោយសារឫទ្ធានុភាពដែលព្រះអម្ចាស់យេស៊ូប្រទានអោយ ។

ជ័យជំនះ ដោយសារព្រះគ្រីស្ត

មុននឹងធ្វើកិច្ចការបំរើខាងព្រលឹងវិញ្ញាណ ដើម្បីរំដោះមនុស្សម្នាក់ខាងព្រលឹងវិញ្ញាណ ត្រូវរកអោយឃើញមូលហេតុដែលអាចធ្វើអោយមនុស្សនោះមានបញ្ហា ។ ត្រូវសាកសួរអោយដឹងពីប្រវត្តិសង្ខេបរបស់អ្នកនោះ ជាពិសេសដឹងថា តើអ្នកនោះមានទាក់ទងជាមួយនឹងអំពើអាបធ្មប់ដែរឬទេ ទោះជាមិនផ្ទាល់ក៏ដោយ ដូចជាការជាប់ទាក់ទងស្នេហាជាមួយអ្នក ដែលធ្វើជាគ្រូធ្មប់ជាដើម ។

នៅពេលធ្វើការរំដោះមនុស្សម្នាក់អោយរួចពីខ្មោច ទោះជាក្នុងកិរិតណាក៏ដោយ ក៏មនុស្សនោះ ត្រូវមានចិត្តចង់ឱ្យបានរួចខ្លួន ហើយជឿថា ព្រះយេស៊ូគ្រីស្តមានឫទ្ធានុភាពរំដោះពួកគេបានដែរ ។

ដូចនេះ ការសំខាន់ គឺត្រូវដឹងថា គេមិនអាចកំចាត់ភាពក្រីក្របាន តែដោយសារបច្ចេកវិទ្យា និង ការអប់រំប៉ុណ្ណោះទេ គឺគេត្រូវប្រើព្រះបន្ទូលព្រះជាម្ចាស់ផងដែរ ។ យើងផ្សាយដំណឹងល្អ ដើម្បីអោយមនុស្សមិនត្រឹមតែអាចចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ តែថែមទាំងនាំអោយគេអាចដោះស្រាយបញ្ហាសង្គមកិច្ច និងសេដ្ឋកិច្ច ដោយប្រើគំនិតដែលមានចែងក្នុងព្រះគម្ពីរទៀតផង ។ គេអាចធ្វើដូចនេះបាន នៅពេលគេបានសង្គ្រោះហើយ ។



© Project WorldReach © SEAN

ពួកខ្មោចបិសាចវាយប្រយុទ្ធនឹងកិច្ចការរបស់ព្រះជាម្ចាស់ ដើម្បីអោយអ្វីៗដែលព្រះអង្គបានបង្កើត ក្លាយជាអាក្រក់ ។ « ដ្បិតមារជាសត្រូវនឹងបងប្អូន ដូចសិង្ហក្រវែល ទាំងគ្រហឹមរកត្របាក់ស៊ីអ្នកណាម្នាក់ » (១ ពេត្រុស ៥:៨) ។

ឧទាហរណ៍ ពួកវាអាច :

- បណ្តាលអោយមានគ្រោះថ្នាក់ ធ្វើអោយកើតមានរឿងដែលមិនធម្មតា បណ្តាលអោយមានជម្ងឺ និង រឿងអាស្រូវ ។
- ធ្វើអោយមនុស្សវង្វេងទៅតាមអំពើមន្តអាគម (កិច្ចការ ១៦:១៦-១៨) ។
- ធ្វើអោយមនុស្សប្រឆាំងនឹងដំណឹងល្អ ឬក៏ធ្វើឱ្យមនុស្សជឿលើគោលលទ្ធិក្លែងក្លាយ (រ៉ូម ១:២១-២២, ២ កូរិនថូស ៤:៤, ១ ធីម៉ូថេ ៤:១, យ៉ូហាន ៨:៤៤) ។
- បណ្តាលអោយមានការបៀតបៀន និង ការដាក់ទោសដល់ពួកគ្រីស្តជន ដែលនាំអោយគ្រីស្តជនបោះបង់ចោលជំនឿរបស់ខ្លួន (ម៉ាថាយ ២៤:៩-១៣, វិវរណៈ ១២:៩-១៧) ។

សូមគូសបន្ទាត់ពីក្រោមសកម្មភាពទាំងប្រាំពីរ ដែលទាក់ទងនឹងគ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់ (សូមប្រយ័ត្ន ព្រោះមានសកម្មភាពបីដែលខុស !) :

ក- និយាយតែពីសេចក្តីពិតជានិច្ច ។

ខ- សិក្សាតាមសកលវិទ្យាល័យ ។

គ- មានជីវិតសុចរិត និង ត្រឹមត្រូវ ។

ឃ- ផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រីស្តប្រាប់អ្នកឯទៀត ។

ង- មានជំនឿលើព្រះជាម្ចាស់ ពេលប្រឈមមុខនឹងខ្មាំងសត្រូវ ។

ច- មានអាគារស្អាតល្អសំរាប់ធ្វើពិធីថ្វាយបង្គំ ។

ឆ- ទុកចិត្តថា យើងបានសង្គ្រោះតាមរយៈជំនឿលើព្រះយេស៊ូ ។

ជ- ទប់ទល់នឹងការល្បួងដោយសារព្រះបន្ទូល ។

ឈ- អធិស្ឋានជាប់ឥតឈប់ឈរ ។

ញ- ធ្វើអោយក្រុមជំនុំមានបទបញ្ជាច្បាស់លាស់ ។

ចំលើយ : ចំលើយ ក, គ, ឃ, ង, ឆ, ជ, ឈ ។

© Project WorldReach © SEAN

នៅក្នុងព្រះគ្រីស្ត យើងបានទទួលការលើកលែងទោសអំពើបាបទាំងអស់ពីពេលមុន និង មានកម្លាំងអាចឈ្នះលើការល្បួង នៅពេលអនាគត ។ ចាប់តាំងពីពេលដែលព្រះគ្រីស្តមានជ័យជំនះលើឈើឆ្កាងមក អារក្សដែលជាអ្នក «ចោទប្រកាន់»យើង ក៏លែងអាចចោទប្រកាន់យើង នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ទៀតដែរ (លូកា ១០:១៨) ។

ដាវនៃព្រះវិញ្ញាណ ដែលជាព្រះបន្ទូលព្រះជាម្ចាស់

ដាវជាអាវុធសំរាប់វាយប្រហារផង សំរាប់ការពារខ្លួនផង ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏ដូចជាដាវដែរ ។ យើងអាចប្រើព្រះ-បន្ទូលព្រះជាម្ចាស់ ដើម្បីការពារខ្លួនប្រឆាំងនឹងគោលលទ្ធិក្លែងក្លាយផង និង វាយប្រហារអារក្ស ដោយប្រើសេចក្តីពិត ដូចដែលព្រះយេស៊ូបានធ្វើប្រកបដោយប្រសិទ្ធិភាព ដើម្បីយកឈ្នះលើមារសាតាំងនៅក្នុងវាលរហោស្ថានផងដែរ (ម៉ាថាយ ៤:១-១១) ។

ការអធិស្ឋាន

ព្រមជាមួយនឹងការប្រើគ្រឿងសស្ត្រាវុធនេះ យើងត្រូវអធិស្ឋានឱ្យបានខ្លាំងក្លាឥតឈប់ឈរ រួមជាមួយគ្រីស្តជនឯទៀត សំរាប់ខ្លួនឯង សំរាប់ក្រុមជំនុំ និង សំរាប់ការរីកសាយដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ ។

- តទល់នឹងទេវទូតដែលព្រះជាម្ចាស់ចាត់អោយមក ដូចជាទេវទូតម្នាក់ ដែលព្រះជាម្ចាស់ចាត់ឱ្យមកជួយលោកដានីអែលដូច្នេះដែរ (ដានីអែល ១០:១-១៥) ។
- បណ្តាលឱ្យរូបកាយមានជម្ងឺអ្វីមួយដូចជា គ ខ្វាក់ (ម៉ាថាយ ៩:៣២, ១២:២២) ឆ្កួតជ្រូក (ម៉ាកុស ៩:១៤-២៩)កោងខ្នង (លូកា ១៣:១០-១៧) ។ល។ ។ (ប៉ុន្តែ មិនមែនជម្ងឺគ្រប់យ៉ាងសុទ្ធតែកើតឡើង ដោយសារសកម្មភាពរបស់ខ្មោចបិសាចទេ) ។ ពួកវាអាចធ្វើអោយមនុស្សវិលវល់ស្មារតីដែរ (១ សាមូអែល ១៦:១៤-២៣) ។

អារក្សក៏មានឈ្មោះថា "មេល្បួង" ដែរ :

(ម៉ាថាយ ៤:៣) ហើយពេលខ្លះ អារក្សធ្វើខ្លួនវា អោយដូចជា *«ទេវទូតនៃពន្លឺ»* ដើម្បី :

- ល្បួងយើងអោយធ្វើបាប (អេភេសូ ២:១-៣) និង ជំរុញនិស្ស័យមនុស្ស ដែលពេញដោយអំពើបាប អោយងើបឡើងធ្វើអាក្រក់ (កិច្ចការ ៥:៣, ១ រាជក្សត្រ ២១:១) ។ មនុស្សដែលធ្វើបាបកាន់តែច្រើន កាន់តែអាចត្រូវអារក្សល្បួងបាន (យ៉ូហាន ៨:៣៤) ។

- បណ្តាលឱ្យចិត្តរបស់បុត្រធីតាព្រះជាម្ចាស់មានការសង្ស័យ និង មិនជឿ (កំណើតពិភពលោក ៣:១-៥, វិវរណៈ ១២:១០-១២) ។
- បណ្តាលអោយមានការទាស់ទែងគ្នា ការច្របូកច្របល់ និង កំហឹងក្នុងចំណោមពួកអ្នកជឿ ដើម្បីរារាំងផែនការរបស់-ព្រះជាម្ចាស់ (ម៉ាថាយ ១៣:២៤-៣០, ៣៦-៤៣) ។
- បង្កើតអោយមានព្រះអំណោយទានខាងព្រលឹងវិញ្ញាណ ក្លែងក្លាយ ដើម្បីនាំអោយពួកអ្នកជឿយល់ច្រឡំ (ម៉ាថាយ ២៤:២៤, ២ កូរិនថូស ១១:១៣-១៥) ។
- ធ្វើអោយអបិយជំនឿគ្រប់ប្រភេទរីកចំរើនឡើង ។

សកម្មភាពអាក្រក់បំផុតរបស់ពួកអារក្សមកលើមនុស្ស គឺល្បួងមនុស្ស មានឥទ្ធិពលលើមនុស្ស ឬ ត្រួតត្រាមនុស្សទាំងស្រុង ។

អារក្សមានឥទ្ធិពលលើមនុស្ស តាមកំរិតផ្សេងៗ ចាប់ពីកំរិតទាបបំផុត គឺបណ្តាលអោយមនុស្សចេះតែមានគំនិតអាក្រក់ជាប្រចាំ រហូតដល់កំរិតខ្ពស់បំផុត គឺមានអារក្សចូល ។

ជើងដែលប្រុងប្រៀបចេញទៅផ្សាយដំណឹងល្អ

ជើងដែលប្រុងប្រៀបចេញទៅផ្សាយដំណឹងល្អអំពីសេចក្តីសុខសាន្ត គ្រប់កន្លែង និង គ្រប់ពេល ។ ធ្វើដូចនេះ នឹងនាំឱ្យមានសេចក្តីសុខសាន្ត បំបាត់កំហឹង និង បំបាត់អំពើឃោរឃៅ ហើយក៏មានន័យថា រក្សាសេចក្តីសុខសាន្ត និង ឯកភាពរវាងគ្រីស្តជនដែរ (ម៉ាថាយ ៥:៩, អេភេសូ ៤:១-៦) ។

ខែលនៃសេចក្តីជំនឿ

គេអាចកាន់ខែលជាប់តាមខ្លួនបាន ដើម្បីការពាររូបកាយទាំងមូល ហើយខែលមានស្បែកពាសពីលើសំរាប់ទប់ព្រួញភ្លើង ។ ដូច្នេះដោយសារជំនឿ យើងអាចការពារខ្លួនបានពីព្រួញភ្លើងខាងព្រលឹងវិញ្ញាណ ដែលអារក្សសាតាំងបាញ់មកយើង ។ ដោយសារជំនឿយើងអាចការពារខ្លួនយើង និង អស់អ្នកដែលយើងទទួលខុសត្រូវ គឺក្រុមជំនុំ ប្តី ឬ ប្រពន្ធ កូនៗ មុខរបរ ។

មួកដែកនៃសេចក្តីសង្គ្រោះ

មួកដែកការពារក្បាល ។ ដូចនេះ នៅពេលដែលមារសាតាំងបាញ់គំនិតភ័យខ្លាច ស្អប់ សង្ស័យ អស់សង្ឃឹម មិនទុកចិត្ត ។ល។ មកលើយើងនោះ សេចក្តីសង្គ្រោះនឹងការពារយើង ។

ក្រវាត់ចង្កេះ ដោយសេចក្តីពិត

ខ្សែក្រវាត់ទប់សំលៀកបំពាក់ និង គ្រឿងសស្ត្រាវុធកុំអោយរបូតចេញ ។ ក្នុងឋានៈជាបុត្រធីតានៃព្រះជាម្ចាស់ យើងត្រូវយកសេចក្តីពិតមកក្រវាត់ចង្កេះ ហើយប្រតិបត្តិតាមព្រះជាម្ចាស់ ដែលមានបន្ទូលថា÷ *«...ខ្ញុំជាសេចក្តីពិត »* ។

បានន័យថា យើងត្រូវជឿ ដោយចិត្តស្មោះត្រង់ និង ទៀងត្រង់ ហើយត្រូវងាកចេញពីការភូតភរ និង ពុតត្បុតនៅក្នុងជីវិតរបស់យើង ពីព្រោះការភូតភរ បើកផ្លូវអោយអារក្សដែលជាមេភូតភរ ។

អាវក្រោះនៃសេចក្តីសុចរិត

អាវក្រោះការពារសរីរាង្គ ដែលសំខាន់បំផុត ។ ដូចនេះ ក្នុងឋានៈយើងជាអ្នកជឿ យើងត្រូវការពារបេះដូង (ចិត្ត) យើង ដោយ «សេចក្តីសុចរិត » បានន័យថា ដោយមានចរិយាមារយាទសុចរិត និង ត្រឹមត្រូវ ។ ម៉្យាងទៀត ក្រុមជំនុំត្រូវធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើអយុត្តិធម៌ ដែលមាននៅក្នុងពិភពលោកយើងនេះដែរ (យ៉ាកុប ២:១-៩, យ៉ាកុប ៥:១-១១, អម៉ូស ២:៦-៨, អម៉ូស ៣:៩-១០, អម៉ូស ៤:១-៥, អម៉ូស ៥:៦-១៥) ។

ឧទាហរណ៍មួយ អំពីឥទ្ធិពលរបស់អារក្សលើមនុស្សម្នាក់ គឺអារក្សបណ្តាលអោយមនុស្សនោះ ធ្វើអំពើបាបដដែលៗម្តងហើយ ម្តងទៀត ទោះជាអ្នកនោះសារភាពកំហុសរបស់ខ្លួន ដោយស្មោះត្រង់ក៏ដោយ ។ ដូច្នេះមនុស្សនោះ មិនគ្រាន់តែត្រូវសារភាពពីកំហុសរបស់ខ្លួនប៉ុណ្ណោះទេ តែត្រូវអធិស្ឋានថែមទៀតជាចាំបាច់ ដើម្បីកំចាត់ឥទ្ធិពលរបស់អារក្ស ។ ក្រៅពីបណ្តាលអោយមនុស្សមានគំនិតអាក្រក់ ឬ ទម្លាប់អាក្រក់ អារក្សអាចត្រួតត្រាលើមនុស្សដែរ គឺប្រើចិត្តគំនិត និង រូបកាយរបស់មនុស្ស ដើម្បីធ្វើអំពើអាក្រក់របស់វា ។

តើខ្មោចបិសាចចូលក្នុងមនុស្ស ដោយរបៀបណា ?

គ្មានក្បួនច្បាប់កំណត់ច្បាស់លាស់ទេ តែមានស្ថានភាពច្រើនបែបយ៉ាង ដែលនាំអោយមារសាតាំងអាចបញ្ចូលឥទ្ធិពលលើមនុស្សបាន ។ ការធ្លាប់មានទំនាក់ទំនងជាមួយនឹងអបិយជំនឿ ឬ វិជ្ជាមន្តអាគម (សេរីភាព ២០:៣-៥, លេវីវិន័យ ១៩:៣១, ២០:៦-៨, និង ទុតិយកថា ១៨:៩-១៤) ។

អំពើផ្សេងៗដែលទាក់ទងនឹងអបិយជំនឿ និង វិជ្ជាមន្តអាគម :

- ការទស្សន៍ទាយតាមតារាសាស្ត្រ និង តាមថ្ងៃ ខែ កំណើត ។
- ការប្រើមន្តអាគមគ្រប់យ៉ាង ។
- ការមើលបាតដៃ ។
- ការព្យាបាលជំងឺ ដោយស្តោះផ្លុំ ឬ ដោយពិធីផ្សេងៗរបស់អារក្ស ។
- ការទាយមើលពីអនាគតតាមសន្លឹកបៀ ។
- ការគោរពវត្ថុសក្តិសិទ្ធិ និង អំពើអាបធ្មប់ ។
- ការសែនព្រេនអោយខ្មោចព្រាយបិសាច ដើម្បីកុំអោយខ្មោចធ្វើទុក្ខ ។

- ទទួលស្គាល់ថា ព្រះគ្រីស្តបានមានជ័យជំនះលើមារសាតាំង និង ខ្មោចព្រាយបិសាច (កូឡូស ២:១៥) ។
- អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ការពារ និង ប្រដាប់ខ្លួន ដោយគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ ។

គ្រឿងសស្ត្រាវុធខាងព្រលឹងវិញ្ញាណរបស់យើង

ព្រះជាម្ចាស់បានផ្តល់គ្រឿងសស្ត្រាវុធអោយបុត្រធីតារបស់ព្រះអង្គ ដើម្បីការពារខ្លួន និង ធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ ។ ពេលប្រឈមមុខប្រយុទ្ធនឹងមារសាតាំង និង អ្នកដែលវាគ្រប់គ្រង យើងត្រូវពឹងលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ មិនមែនពឹងលើអំណាចរបស់ខ្លួនយើងផ្ទាល់ឡើយ ហើយពាក់គ្រឿងសស្ត្រាវុធទាំងអស់ដែលព្រះជាម្ចាស់បានប្រទានដល់យើង ។ សូមអានបទគម្ពីរអេភេសូ ៦:១០-២០ ។



គ្រីស្តជនម្នាក់ៗត្រូវត្រៀមខ្លួន ដោយសារឫទ្ធានុភាពដែលព្រះគ្រីស្ត បានប្រទានដល់គេ ដើម្បីជួយមនុស្សដែលត្រូវមារសាតាំងធ្វើបាប ។ ប៉ុន្តែ គេត្រូវបំពេញកិច្ចការបំរើនេះ ដោយរឹងមាំជាក់លាក់ ហើយក្នុងករណីដែលធ្ងន់ធ្ងរខ្លាំង គេគួរតែទៅសុំជំនួយពីគ្រីស្តជនចាស់ទុំ ដែលធ្លាប់ធ្វើការងារនេះបានជោគជ័យរួចមកហើយ ។

ទោះជានៅក្នុងករណីណាក៏ដោយ មុននឹងចូលធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ គ្រីស្តជនអ្នកបំរើគ្រប់រូបត្រូវ :

- លន់តួសារភាព ហើយឈប់ប្រព្រឹត្តអំពើបាបគ្រប់យ៉ាង ។
- បើអាចធ្វើបាន សូមអធិស្ឋាន និង តមអាហារជាមួយគ្រីស្តជនឯទៀត (ម៉ាកុស ៩:២៩) ។
- ប្រកាសបញ្ជាក់ពីអំណាច ដែលព្រះជាម្ចាស់បានប្រទានអោយ « ដើម្បីដេញខ្មោច » (ម៉ាកុស ៣:១៣-១៥, លូកា ១០:១៧-២០) ។
- បន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់ ដោយពឹងផ្អែកតែលើឫទ្ធានុភាពរបស់ព្រះអង្គ ។

- ការខាបព្រលឹង ។
- ការបន់ស្រន់ព្រលឹងដូនតា ។
- ការចូលរួប ។
- ការសមាធិ (លំហាត់ និង ទ្រឹស្តីទស្សនៈវិទ្យា) ។
- ការធ្វើអំពើដាក់អ្នកដទៃ ។
- ការសាក់រូបយ័ននៅលើខ្លួនប្រាណ ។
- ការសែនលោកខែ និង ក្បាលទឹក ។
- ការថ្វាយបង្គំទេវតា ទេព្រ័ក្ស (អ្នករក្សាព្រៃ) ។
- ការរងទុក្ខលំបាកខុសពីធម្មតា ពេលនៅជាកុមារតូច ដូចជាត្រូវបងប្អូន ឬ ឪពុករំលោភ ឬក៏ត្រូវមនុស្សចាស់ធ្វើបាបដោយរបៀបផ្សេងៗទៀត ឬក៏មានឪពុកម្តាយដែលចេះតែស្រវឹងស្រា ។ ការរងទុក្ខលំបាក ដោយសារអំពើទាំងអស់នោះ ច្រើនតែបណ្តាលឱ្យអ្នករងគ្រោះមានកំហឹងខ្លាំង ទប់មិនបាន សួរខ្លួនឯង និង សួរអ្នកដទៃ ។ មនុស្សដែលបានទទួលហេតុការណ៍នេះ ងាយទទួលឥទ្ធិពលរបស់មារសាតាំងណាស់ ។

- ធ្លាប់រស់ក្នុងអំពើបាប ដូចជាការលោភលន់ចង់បានទ្រព្យសម្បត្តិ កាមគុណថោកទាប ឃាតកម្ម ការប្រមឹកស្រា ការញៀនគ្រឿងញៀន និង ការប្រាសចាកសីលធម៌ ដូចជាអំពើអាសអាភាស ការរួមរស់ជាមួយគ្នា ដោយឥតរៀបការ ការផិតក្បត់ ការតែងខ្លួនជាខ្មើយ ការរួមភេទដូចគ្នា ការរួមរ៉ក្សជាមួយសត្វ ។ល។ ។
- អារម្មណ៍ដែលចេះតែមានជាប់ជានិច្ចហួសហេតុ ដូចជាការភ័យខ្លាច ការធ្លាក់ទឹកចិត្ត ការព្រួយបារម្ភ ។ល។ ។
- ធ្លាប់មានទំនាក់ទំនងជាមួយមារសាតាំង ដោយគោរពបូជាមារសាតាំង ។
- ឥទ្ធិពលរបស់គ្រួសារ ។ សេរីភាព ២០:៥ ចែងថា÷*«យើងជាព្រះអម្ចាស់ ជាព្រះរបស់អ្នក យើងមិនចង់អោយអ្នកជំពាក់ចិត្តនឹងព្រះណាផ្សេង ក្រៅពីយើងឡើយ ។ ប្រសិនបើនរណាក្បត់ចិត្តយើង យើងនឹងដាក់ទោសគេចាប់ពីឪពុករហូតដល់កូនចៅបីបួនតំណ »* ។ គេឃើញថា សេចក្តីនេះជាការពិតមែន គឺកូនចៅរបស់ពួកអ្នកប្រមឹកភាគច្រើនក្លាយជាអ្នកប្រមឹកដែរ ហាក់ដូចជាអារក្សមានឥទ្ធិពល ក្នុងរឿងហេតុដូចនេះដែរ ។

យើងត្រូវធ្វើសង្គ្រាមនៅក្នុងក្រុមជំនុំ ដែលជាទីកន្លែងដែលមារសាតាំងធ្វើសកម្មភាពខ្លាំងជាងគេ (វិវរណៈ ១២:១២-១៧) ដោយណែនាំអ្នកជឿឱ្យចេះប្រើគ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់ (អេភេសូ ៦:១០-១៨) ។

យើងត្រូវធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ នៅក្នុងសហគមន៍ជាពិសេស នៅកន្លែងដែលមានអំពើបាប និង មានការប្រឆាំងនឹងដំណឹងល្អខ្លាំងណាស់ ។ ក្រុមជំនុំត្រូវបំបាក់បល្ល័ង្ករបស់មារសាតាំង នៅទីកន្លែងនោះ ដោយអធិស្ឋាន និង តមអាហារ ព្រមទាំងប្រកាសពីជ័យជំនះរបស់ព្រះគ្រីស្ត និង ពីបរាជ័យរបស់អារក្ស (វិវរណៈ ២:១៣) ។ យើងក៏ត្រូវអធិស្ឋានសំរាប់រាជរដ្ឋាភិបាល សុំសន្តិភាព យុត្តិធម៌ និង សុំអោយផ្លូវបើកសំរាប់អោយយើងអាចផ្សាយដំណឹងល្អដែរ (១ ធីម៉ូថេ ២:១-៧) ។

«ការរំដោះមនុស្សអោយរួចពីឥទ្ធិពលអារក្ស» ជាផ្នែកមួយនៃសកម្មភាពរបស់ព្រះរាជ្យរបស់ព្រះជាម្ចាស់ ដើម្បីយកជ័យជំនះលើមារសាតាំង ។ ព្រះរាជ្យ បុទ្ធានុភាព និង សិរីរុងរឿងជារបស់ព្រះជាម្ចាស់ មិនមែនជារបស់យើងទេ ។ ហេតុដូច្នេះហើយ កិច្ចការនេះជារបស់ព្រះជាម្ចាស់ គឺមិនមែនជាកិច្ចការរបស់យើងទេ ។

សង្គ្រាមខាងព្រលឹងវិញ្ញាណ

យើងធ្វើអោយរាជ្យរបស់មារសាតាំងខ្វចខាតខ្លាំងបំផុត ដោយសារយើងផ្សាយដំណឹងល្អប្រាប់លោកីយ៍ ។ យើងត្រូវតែចាំជានិច្ចថា បើយើងស្តាប់បង្គាប់តាមព្រះអម្ចាស់ ដោយផ្សាយដំណឹងល្អនោះ គឺយើងរស់នៅ ដោយប្រយុទ្ធជាមួយកម្លាំងរបស់ភពងងឹតជាប់ជាប្រចាំ ។ ដើម្បីធ្វើសង្គ្រាមនេះអោយបានជោគជ័យ យើងត្រូវតែអធិស្ឋានជាប់ជាប្រចាំ ដោយតមអាហារ ប្រកាសផ្សាយដំណឹងល្អ ឥតឈប់ឈរ និង ប្រតិបត្តិតាមព្រះបន្ទូល ដោយហ្មត់ចត់ ។

យើងត្រូវធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ ជាបន្តរហូត ក្នុងជីវិតរបស់យើងផ្ទាល់ ដោយថ្វាយខ្លួនយើងរាល់ថ្ងៃទៅព្រះជាម្ចាស់ ទុកជាយញ្ញបូជាដ៏មានជីវិត ហើយសំអាតជីវិតយើងកុំអោយមានគំនិតអាក្រក់ និង ការប្រព្រឹត្តអាក្រក់ ដោយបន្តប្រយុទ្ធដូចនេះ ។

យើងត្រូវធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ ក្នុងក្រុមគ្រួសារបស់យើង ដោយស្រឡាញ់ប្តី ឬ ប្រពន្ធយើង និង កូនៗយើង ហើយអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង អធិស្ឋានជាមួយសមាជិកក្រុមគ្រួសារ ជារៀងរាល់ថ្ងៃ ។

- រងទុក្ខវេទនា ដោយសារបណ្តាសាដែលសាច់ញាតិ ឬ គ្រូ ឬ អ្នកជិតខាងដាក់អោយ ឬ ដោយសារអំពើអាបធ្មប់គ្រប់យ៉ាង ។



តើយើងអាចមើលស្គាល់មនុស្សខ្មោចចូល ដោយរបៀបណា

មានគ្រីស្តជនខ្លះច្រឡំថា ជម្ងឺរបស់រូបកាយ ឬ របស់ខួរក្បាល សុទ្ធតែជាឥទ្ធិពលរបស់ «ខ្មោចចូល» ។ ឧទាហរណ៍ អ្នកខ្លះច្រឡំថា ជម្ងឺរឹងសរសៃឈាមរបស់ខួរក្បាល ជម្ងឺចាស់វង្វេងវង្វាន់ ឬ ជម្ងឺខ្វះលំនឹងគីមី (គឺជំងឺខ្វះសារជាតិគីមីដែលចាំបាច់ សំរាប់ទ្រទ្រង់សរីរាង្គកាយ) ជាសញ្ញារបស់មនុស្សខ្មោចចូល ។ ប៉ុន្តែជម្ងឺប្រភេទនេះ មិនមែនខ្មោចចូលទេ គ្រាន់តែជម្ងឺប្រភេទនេះមានឥទ្ធិពលអាក្រក់លើបុគ្គលិកលក្ខណៈមនុស្ស ដោយបង្កើតរោគសញ្ញា ដែលប្រហាក់ហែលនឹងរោគសញ្ញារបស់មនុស្សខ្មោចចូលដែរប៉ុណ្ណោះ ។ ដូចនេះ យើងត្រូវតែប្រុងប្រយ័ត្នក្នុងការវិនិច្ឆ័យបញ្ហានិមួយៗ ។ នៅក្នុងករណីខ្លះ យើងចាំបាច់ត្រូវទៅសួរយោបល់គ្រូពេទ្យសិន ។

សូមអាន លូកា ៨:២៦-៣៩ ។ មនុស្សដែលទទួលឥទ្ធិពលរបស់អារក្ស អាចមានលក្ខណៈដូចខាងក្រោមនេះ :

- មនុស្សខ្មោចចូលនៅអាចគ្រប់គ្រងលើជីវិតខ្លួនឯងបានខ្លះ ។ បុរសដែលខ្មោចចូល បានចេញមករកព្រះយេស៊ូ ប្រហែលជាសង្ឃឹមថាអាចជាវិញបាន (ខ ២៧) ។

ព្រះរាជ្យរបស់ព្រះជាម្ចាស់



ទោះជាមានអំពើអាក្រក់គួរអោយខ្លាច ដូចដែលយើងបាននិយាយនោះក៏ដោយ ក៏យើងត្រូវមើលឃើញសេចក្តីពិតដែលថា ព្រះ-យេស៊ូគ្រីស្តរបស់យើងឈ្នះលើមារសាតាំង ដោយសុគតនៅលើឈើឆ្កាង និង ដោះលែងពួកអ្នក ដែលវាសង្កត់សង្កិន អោយរួចហើយដែរ (លូកា ៤:១៨-២០, អេភេសូ ១:២០-២២, កូឡូស ២:១៣-១៥, ហេប្រឺ ២:១៤-១៥) ។

ចំណែកឯព្រះគ្រីស្ត *«ព្រះអង្គបានយាងឡើងទៅស្ថានខ្ពស់ ព្រះអង្គបាននាំពួកជាប់ជាឈ្លើយទៅជាមួយ...»* (អេភេសូ ៤:៨) ។ ដោយសារយើងចូលរួមក្នុងជ័យជំនះជាមួយព្រះគ្រីស្ត ទើបយើងអាចដើរទៅមុខ ដើម្បីពង្រីកជោគជ័យរបស់ព្រះគ្រីស្ត ។

© Project WorldReach © SEAN

បានរួចផុតពីអំណាចរបស់អារក្សហើយ តែយើងនៅតែអាចទទួលឥទ្ធិពលរបស់អំណាចនោះទៀត ប្រសិនបើយើងធ្វេសប្រហែស មិនប្រើគ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់ (អេភេសូ ៦:១៣-១៨) ។

ស្តេចសាអ៊ូលជាស្តេចនៃសាសន៍អ៊ីស្រាអែល ដែលព្រះវិញ្ញាណដ៏វិសុទ្ធលាបប្រេងអភិសេកអោយថ្លែងព្រះបន្ទូល (១ សាមូអែល ១០:១, ៩-១៣) ។ ប៉ុន្តែ ក្រោយដែលស្តេចសាអ៊ូលលែងស្តាប់បង្គាប់ព្រះជាម្ចាស់ ដែលបានចែងទុកក្នុង ១ សាមូអែល ជំពូក ១៥ គាត់ក៏ត្រូវវិញ្ញាណអាក្រក់មួយធ្វើបាប (១ សាមូអែល ១៦:១៤) ហើយគាត់មានលក្ខណៈដូចជាមនុស្សដែលមានខ្មោចចូលជាច្រើន គឺផ្ទុះកំហឹងឆេវឆាវ មានចិត្តចង់សម្លាប់មនុស្ស និង ភ័យខ្លាចហួសហេតុ ។

ប៉ុន្តែ យើងអាចនិយាយដោយជាក់ច្បាស់ថា គ្រីស្តជនដែលពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ :

- ☐ អាចត្រូវមារសាតាំងត្អូតត្រា គឺខ្មោចចូល ។
- ☐ អាចទទួលឥទ្ធិពលពីមារសាតាំង តែមិនអាចមាន «ខ្មោចចូល »ទេ ។

ចំលើយ : បុត្រធីតាពិតរបស់ព្រះជាម្ចាស់ អាចទទួលឥទ្ធិពលខ្លះពីបិសាច តែមិនដែលមាន «ខ្មោចចូល » ឡើយ ។

- ពួកបិសាចបញ្ចេញឥទ្ធិពលអាក្រក់លើមនុស្ស ។ ជួនកាលខ្មោចបណ្តាលអោយមនុស្សទៅជាគ ឬ ថ្លង់ (ម៉ាកុស ៩:២៥, លូកា ១១:១៤) ។ ក្នុងករណីផ្សេងទៀត វាបណ្តាលឱ្យមនុស្សប្រកាច់ប្រកិនដួចឆ្លងត្រួក ដោយដួលទៅដី រឹងខ្លួនស្លុក ស្រែកបែកពពុះមាត់ និង សង្កៀតធ្មេញ (ម៉ាកុស ៩:១៧-១៨) ។ ឧទាហរណ៍ លូការ ៨:២៨ ចែងថា : បុរសខ្មោចចូល *«ក្រាបទៀបព្រះបាទាព្រះអង្គ ហើយស្រែកយ៉ាងខ្លាំង »* ។
- ជួនកាល ពួកបិសាចធ្វើឱ្យមនុស្សធ្វើបាបខ្លួនឯង អោយឈឺចាប់ ។ ឧទាហរណ៍ ម៉ាកុស ៥:៥ ចែងថា បុរសខ្មោចចូល យកដុំថ្មមកអារសាច់ខ្លួនឯង ។ បិសាចអាចធ្វើបាបមនុស្សរបៀបនេះ ក្នុងរយៈពេលពីរបីនាទី ឬ ច្រើនថ្ងៃ ហើយវាច្រើនតែបណ្តាលឱ្យមនុស្សធ្វើដូចនេះ ជាពិសេសនៅពេលមានវត្តមានរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដូចជានៅពេលប្រជុំគ្នាក្នុងព្រះវិហារ (ម៉ាកុស ១:២១-២៤) ។
- មនុស្សមានខ្មោចចូល ច្រើនតែមានកម្លាំងខ្លាំងខុសពីធម្មតា ។ ឧទាហរណ៍ លូកា ៨:២៩ ចែងថា បុរសនៅក្រុងកេរ៉ាសា កាច់ច្រវាក់បាន ។

- បិសាចអាចនិយាយប្រឆាំងនឹងព្រះយេស៊ូ តាមរយៈមនុស្ស បាន ។ នៅក្នុង លូកា ៨:២៨ បិសាចនិយាយថា÷ *«ឱព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ? សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំអី!»* ។

- ជួនកាល មនុស្សខ្មោចចូលនិយាយដោយសំឡេងខុសផ្សេងពីសំឡេងដើមរបស់ខ្លួន ហើយជួនកាលនិយាយភាសាផ្សេងពីភាសាកំណើតរបស់ខ្លួនដែរ ។ ឧទាហរណ៍ មនុស្សអាចនិយាយសំឡេងស្រី ឬក៏ធ្វើជាសំឡេងសត្វ ។ នៅក្នុង ខ ២៨ បុរសនោះ *«ស្រែកយ៉ាងខ្លាំង»* មិននិយាយតាមធម្មតាទេ ។

- មនុស្សខ្មោចចូលច្រើនតែមានចំណេះដឹង ឬ បទ្ធានុភាពដែលមនុស្សធម្មតាគ្មាន ។ ឧទាហរណ៍ បុរសនោះគ្រាន់តែឃើញព្រះយេស៊ូ គាត់ដឹងថា ព្រះអង្គជាអ្នកណាភ្លាម ទោះជាគាត់មិនដែលធ្លាប់ជួបនឹងព្រះអង្គពីមុនមកក៏ដោយ ។

តើគ្រីស្តជនអាច "មានខ្មោចចូល" ដែរឬទេ ?

ព្រះជាម្ចាស់ជាព្រះអម្ចាស់ (ម្ចាស់) លើបុត្រធីតារបស់ព្រះអង្គ និង ការពារពួកគេ ។ ព្រះអង្គមិនអនុញ្ញាតិឱ្យមារសាតាំងធ្វើបាបមនុស្សឱ្យហួសពីកិរិតមួយទេ ដូចជាក្នុងករណីរបស់លោកយ៉ូប ។ ពួកបិសាចវាយប្រហារគ្រីស្តជនទាំងអស់ ហើយគ្មាននរណាម្នាក់ដែលមិនត្រូវល្បួងនោះទេ សូម្បីតែព្រះយេស៊ូក៏ត្រូវអារក្សល្បួងពេលដែលព្រះអង្គគង់នៅលើផែនដីដែរ ! ។ ប៉ុន្តែ យើងជាគ្រីស្តជនស្ថិតនៅក្នុងព្រះរាជ្យផ្សេងពីរាជ្យរបស់អារក្ស ហើយយើងជាបុត្រធីតារបស់ព្រះជាម្ចាស់ ។ យើងជាមនុស្សថ្មី និង ជាព្រះវិហាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (១ កូរិនថូស ៦:១៩, ២ កូរិនថូស ៥:១៧) ។ ហើយបិសាចមិនអាចគ្រប់គ្រងលើមនុស្ស ដែលមានព្រះវិញ្ញាណដ៏វិសុទ្ធគង់ជាមួយទេ ។

ប៉ុន្តែ បើសិនជាគ្រីស្តជនបន្តធ្វើអំពើបាបខ្លាំងៗ និង មិនព្រមលន់តួសារភាពអំពើបាបទាំងនោះទេ អ្នកនោះអាចទទួលឥទ្ធិពលពីបិសាច ហើយងាកចេញឆ្ងាយពីផ្លូវរបស់ព្រះជាម្ចាស់ ។ ទោះជាបិសាចមិនអាចគ្រួតគ្រាគ្រីស្តជននោះទាំងស្រុងក៏ដោយ ក៏បិសាចអាចវាយយកបានបុគ្គលិកលក្ខណៈមួយផ្នែករបស់គ្រីស្តជននោះដែរ ។ យើង

- មនុស្សខ្មោចចូលច្រើនតែលែងមានសីលធម៌ ឬ ប្រព្រឹត្តអំពើសៅហ្មង ។ ឧទាហរណ៍ ដូចជាបុរសនៅក្រុងកេរ៉ាសាលែងខ្លាស់អៀនអ្វីទាំងអស់ *«គាត់មានខ្មោចចូល ហើយមិនស្លៀកពាក់ មិនរស់នៅក្នុងផ្ទះតាំងពីយូរមកហើយ »* (ខ ២៧) ។
- មនុស្សម្នាក់អាចមានខ្មោចច្រើនចូល ។ នៅពេលដែលព្រះអម្ចាស់សួរទៅបុរសនៅកេរ៉ាសាថា÷ *«ឯងឈ្មោះអី ? »* ។ ខ្មោចឆ្លើយថា÷ *«ទូលបង្គំឈ្មោះកងទ័ព »* ។ វាឆ្លើយដូច្នេះព្រោះមានខ្មោចជាច្រើនចូលក្នុងបុរសនោះ (ខ ៣០) ។ (កាលនោះកងទ័ពរ៉ូម៉ាំងមានទាហានចំនួន ៦ ពាន់នាក់) ។
- ឥរិយាបថដែលពេញដោយអំពើបាប ដូចជា ការស្អប់ខ្ពើមឯង ការមិនទទួលអោយអ្នកដទៃអត់ទោស គំនុំ ការអន់ចិត្ត និងការមាក់ងាយ ។
- ជម្ងឺរ៉ាំរ៉ៃខ្លះ ជាពិសេស ជម្ងឺដែលកើតមានតពូជពង្សច្រើនតំណមកហើយ ដែលវិជ្ជាពេទ្យពន្យល់មិនកើត ។
- ការបដិសេធព្រះនាមព្រះយេស៊ូគ្រីស្តហួសហេតុ ។



យើងអាចធ្វើអោយមានផលអាក្រក់លើមនុស្ស (ពិសេសលើក្មេងៗ) បើសិនជាយើងប្រាប់ពួកគេថា ពួកគេមានអារក្សចូល តែតាមពិតពួកគេគ្មានអារក្សចូលទេ ។ ព្រោះពួកគេអាចយកលេសថា ពួកគេអាចប្រព្រឹត្តអាក្រក់ ដោយសារអារក្ស ដែលនាំអោយគេមិនទទួលខុសត្រូវចំពោះខ្លួន ។ មួយវិញទៀត ការចាប់អារម្មណ៍ហួសហេតុពេកលើវិញ្ញាណអាក្រក់នោះ អាចទាក់ទាញវិញ្ញាណអាក្រក់ និង នាំអោយវិនាសអន្តរាយកាន់តែខ្លាំង ។ នៅក្នុង លូកា ១០:២០ ព្រះយេស៊ូដាស់តឿនសាវ័ករបស់ព្រះអង្គ កុំអោយចាប់អារម្មណ៍ហួសហេតុលើខ្មោចព្រោយបិសាច ។

យើងត្រូវប្រយ័ត្ន !

យើងមិនត្រូវចេះតែយល់ថា ឲ្យតែអ្នកណាម្នាក់មានបញ្ហា នោះសុទ្ធតែបណ្តាលមកពីវត្តមានរបស់អារក្សនោះទេ ។ មនុស្សគ្រប់គ្នាសុទ្ធតែធ្វើបាប ហើយយើងមិនអាចលើកដាក់គិតថាអំពើបាបគ្រប់យ៉ាង សុទ្ធតែបណ្តាលមកពីវិញ្ញាណអាក្រក់នោះទេ ។ បើយើងសង្ស័យថាជាឥទ្ធិពលរបស់អារក្ស យើងគ្រាន់តែអធិស្ឋានទូលសូមអោយព្រះជាម្ចាស់រំដោះអ្នករងគ្រោះ និង សុំអោយពួកអ្នកជឿ ដែលមានបទពិសោធន៍ក្នុងការប្រោសជំងឺរបៀបនេះ ជួយយើងប៉ុណ្ណោះ ។



មនុស្សខ្មោចចូល រស់នៅស្របតាមការស្រមើស្រមៃខុសពីការពិតខ្លាំងណាស់ ហើយការស្រមើស្រមៃដូចនេះ បំផ្លាញជីវិតអោយវិនាស ដោយនាំអោយពួកគេមានទាំងគំនិតផ្តេសផ្តាស មិនសមស្រប និង មានទាំងការប្រព្រឹត្ត ដែលនាំឲ្យវិនាស ។ នៅពេលដែលពួកគេត្រូវប្រឈមមុខនឹងសេចក្តីពិតអំពីព្រះគ្រីស្ត ពួកគេច្រើនតែក្លាយជាមានចិត្តច្របូកច្របល់ ជ្រួលច្រាល មិនសមហេតុផល ។



© Project WorldReach © SEAN